ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៤២

ចុះថ្ងៃទី២៨ខែមិនា ឆ្នាំ២.000 សាលឧទ្ធរណ៍ប្រជារាស្ត្រខ្មែរ

សាលដីកា តុលាការកំពូល

លេខ : ២២

ចុះថ្ងៃទី២៩ខែមករាឆ្នាំ២.00៤ បានបើក សវនាការ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ ២.00៤ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២ - លោក ស៊ិន ឌឹម ជាចៅក្រម

៣ - លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៤ - លោក យស់ សូខឿន ជាចៅក្រម

៥ - លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

លោក ឡេង វុធ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពី សាលដីការដ្ឋប្បវេណីលេខៈ ៨៣០ ចុះថ្ងៃទី២៥ខែវិច្ឆកា ឆ្នាំ១៩៩៩ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ :៥៨១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់ សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ទុយ សារ៉េត ជាម្ចាស់បណ្តឹងសាទុក្ខ ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ី ធ្វើស្រែ មានទីលំនៅ ភូមិអង្គតាទួ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ឪពុកឈ្មោះទុយ ទឹម "រ" ម្តាយឈ្មោះ ទុយ ជឹម "រ" ។

និង ចុងចម្លើយឈ្មោះ ណុប រិត ជាចុងបណ្តឹងសាទុក្ខ ភេទស្រី អាយុ៣៤ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅ ភូមិអង្គតាទួ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ឪពុកឈ្មោះណុប ជា "ស" ម្តាយឈ្មោះ ណុប ខាត់ "ស" តំណាងដោយកូនឈ្មោះ យ៉ែម អឿន។

កម្មវត្ថុបណ្តឹង : ប្តឹងបដិសេធ ដីកាសំរេចលេខ : 0៣ដក ចុះថ្ងៃទី 0៩-0២-៩៩ របស់អភិបាល

ស្រុកត្រាំកក់ សុំទាមទារដីស្រែមួយរបប និង សុំទាមទារដីលំនៅដ្ឋាន ។

បានឃើញ បណ្ដឹងសាទុក្ខលេខ :៣៥ ចុះថ្ងៃទី២៤ខែមករាឆ្នាំ២០០០របស់ឈ្មោះ ទុយ សារ៉េត បានប្ដឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ : ១៤២ ចុះថ្ងៃទី២៨ ខែមិនា ឆ្នាំ២.០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១១-០២-៩៨ របស់ដើមចោទថា ខ្លួនសុំប្ដឹងបដិសេធដីកាសំរេចលេខ : ០៣ដ.ក ចុះថ្ងៃទី០៩-០២-៩៨ ទាមទារដីស្រែមួយរបប និង ដីលំនៅដ្ឋានពាក់កណ្ដាល ដោយអាងហេតុថា ដីទាំងពីរប្រភេទនេះត្រូវគ្រប់គ្រងដោយឈ្មោះ ណុប វិត និង ប្ដី តែដោយគេទាំងពីរបែកលំនៅគ្នា ឈ្មោះ ឆាង សារឿន ជាប្ដីក៏បានហៅខ្លួនទៅរស់នៅលើដីនោះតាំងពីឆ្នាំ១៩៨៨មក លុះដល់សព្វថ្ងៃអ្នកទាំងពីររួមរស់នៅជាមួយគ្នាវិញ ស្រាប់តែមានឈ្មោះ ណុប វិត ទាមទារយកដីវិញ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ :១០ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ របស់ តុលាការខេត្ត តាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១១-០២-១៩៩៨ របស់ដើមចោទឈ្មោះ ទុយ សារ៉េត ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - ប្រគល់ដីលំនៅដ្ឋានដែលមានទំហំ ១.៣៥០$m^2$ និង ដីស្រែចំនួន ៥.៣៩០$m^2$ ដែលស្ថិតនៅភូមិអង្គតាទួ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ឱ្យទៅឈ្មោះ ណុប វិត ជាអ្នកកាន់ កាប់គ្រប់គ្រងចាប់ពេលនេះតទៅ ។ កាលបើផុតបណ្ដឹង បង្គាប់ឱ្យឈ្មោះ ទុយ សារ៉េត រុះរើផ្ទះចេញ ពីដីលំនៅ ដ្ឋានរបស់ណុប វិត ក្នុងរយៈពេល៣០ថ្ងៃជាកំណត់ ។

៣ - ប្រាក់ប្រដាប់ក្ដី ៧.០០០រៀល ដើមចោទបានបង់រួចហើយប្រាក់នេះត្រូវរឹបអូស ។ កាលបើផុតបណ្ដឹងឧទ្ធរណ៍បង្គាប់ឱ្យឈ្មោះ ទុយ សារ៉េត បង់ប្រាក់ពន្ធសមាមាត្រស្មើ ១%លើតម្លៃដីទំនាស់ មានដីស្រែ ២តម្លឹងមាស ដីលំនៅដ្ឋាន០១តម្លឹងមាស ប្រាក់នេះជាថវិការដ្ឋ ៨០% និង ២០%រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះចុងចម្លើយ កំបាំងមុខដើមចោទ បើកផ្លូវប្ដឹងទាស់រយៈពេល១៥ថ្ងៃ និង បន្ថែមរយៈពេល២ខែទៀត សំរាប់ប្ដឹងឧទ្ធរណ៍ គិតចាប់តាំងពីថ្ងៃទទួលដំណឹងពីសាលក្រមនេះ ។

បានឃើញ បណ្ដឹងទាស់លេខៈ ០៨របស់ដើមចោទឈ្មោះ ទុយ សារ៉េត ចុះថ្ងៃទី១០-០៥-១៩៩៩ សុំប្ដឹងជំទាស់ នឹងសាលក្រមលេខ : ១០ ចុះថ្ងៃទី២៧-៤-៩៩ របស់តុលាការខេត្តតាកែវទាំងមូល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខៈ ១៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១១-០២-១៩៩៨ របស់ដើមចោទឈ្មោះ ទុយ សារ៉េត ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - ប្រគល់ដីលំនៅដ្ឋានដែលមានទំហំ ១.៣៥០m$^2$ និង ដីស្រែសចំនួន ៥.៣៥០m$^2$ ដែលស្ថិតនៅភូមិអង្គតានូ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ឱ្យទៅឈ្មោះ ណុប រិត ជាអ្នកកាន់កាប់គ្រប់គ្រងចាប់ពីពេលនេះតទៅ ។ កាលបើផុតបណ្ដឹងឧទ្ធរណ៍បង្គាប់ឱ្យឈ្មោះ ទុយ សារ៉េត រុះរើផ្ទះចេញពីដីលំនៅដ្ឋានរបស់ ណុប រិត ក្នុងរយៈពេល ៣០ថ្ងៃជាកំណត់ ។

៣ - ប្រាក់ប្រដាប់ក្ដី ៧.០០០រៀល ដើមចោទបានបង់រួចហើយ ប្រាក់នេះត្រូវរឹបអូស ។ កាលបើផុតបណ្ដឹងឧទ្ធរណ៍បង្គាប់ឱ្យឈ្មោះ ទុយ សារ៉េត បង់ប្រាក់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ មានដីស្រែ ២តម្លឹង និង ដីភូមិ ១តម្លឹង ប្រាក់នេះជាថវិការដ្ឋ៨០% និង វង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង ចុងចម្លើយ បើកផ្លូវប្ដឹងឧទ្ធរណ៍ រយៈពេល២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍លេខៈ ១០ ចុះថ្ងៃទី០៧ខែកក្កដាឆ្នាំ១៩៩៩របស់ឈ្មោះ ទុយ សារ៉េត បានប្ដឹងមិនសុខចិត្ត នឹងសាលក្រមលេខ : ១៦ ចុះថ្ងៃទី២២-០៦-១៩៩៩ របស់ តុលាការ ខេត្តតាកែវ ត្រង់ចំណុច នៃសេចក្ដី សំរេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខៈ៨៣០ចុះថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ១៩៩៩របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលបណ្ដឹងឧទ្ធរណ៍លេខៈ ១០ចុះថ្ងៃទី០៧-០៧-៩៩ របស់ឈ្មោះ ទុយ សារ៉េត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សសាលក្រមរដ្ឋប្បវេណីលេខៈ ១៦ ចុះថ្ងៃទី២២-០៦-៩៩ របស់តុលាការខេត្តតាកែវ ទុកជាបានការពេញទាំងមូល ។

៣ - រឹបអូសប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ២.៥៥០រៀល វង្វាន់ក្រឡាបញ្ជីកាន់ហ៊ឹបប្រាក់ចំនួន

៤៥០រៀល.រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការចំនួន៥០០០រៀល សរុប ១៣.០០០រៀល ។

៤ - សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី។ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខៈ ៣៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០០របស់ឈ្មោះទុយ សារ៉េត បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញ សារណារបស់ឈ្មោះទុយ សារ៉េត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០០ ។

បានឃើញ សារណាឆ្លើយតបរបស់ឈ្មោះ ណុប រិត ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០០។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយកមកពិចារណា ។

សាលដីការបស់សាលាឧទ្ធរណ៍ដែលសំរេចសេក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

ឈ្មោះ ទុយ សារ៉េត បានឆ្លើយថា : ព្រោះការកាត់សេចក្តីកន្លងមកមិនត្រឹមត្រូវតាមច្បាប់ ឡើយដោយដីនេះខ្លួនបានគ្រប់គ្រង និង ថែរក្សាព្រមទាំងមើលជម្ងឺប្តីរបស់ឈ្មោះ ណុប រិត និង ម្តាយក្មេក របស់គេទៀត កាលពីអ្នកទាំងពីរនេះមានជម្ងឺឈ្មោះ ណុប រិត ជាប្រពន្ធមិនបាននៅជួយមើលថែទាំជម្ងឺពួក គាត់ទេ គឺឈ្មោះ ណុប រិត បានរត់ចេញបាត់អស់រយៈពេលដប់ឆ្នាំ ដោយយកដីស្រែលក់ខ្លះ និង បានបញ្ចាំខ្លះ ហើយទៅបាត់ ចំណែកដីដែលឈ្មោះ ណុប រិត បញ្ចាំគេនោះខ្លួនបានយកប្រាក់របស់ខ្លួនលោះយកមកវិញ ។ នៅឆ្នាំ១៩៩៨ ពេលដែលគាត់ត្រឡប់មកវិញ បានទាមទារយកដីវិញទាំងអស់ គឺនៅពេលនោះខ្លួនបានប្រគល់ ឱ្យគាត់វិញអស់ហើយ គឺខ្លួនទុកតែដីដែលម្តាយក្មេក ណុប រិត ឈ្មោះ សុស មុំ បានប្រគល់មកឱ្យខ្លួនកាន់កាប់ គ្រប់គ្រងមុនពេលគាត់ស្លាប់ប៉ុណ្ណោះ ។

សូមឯកឧត្តម មេត្តាប្រគល់ដីដែលខ្លួនកំពង់គ្រប់គ្រងមកឱ្យខ្លួនកាន់កាប់តាមច្បាប់ ។

ឈ្មោះ ឃៃ អឿន តំណាងឱ្យម្តាយ បានឆ្លើយថា : ខ្លួនមិនបានប្រគល់ដីនេះឱ្យទៅគាត់ទេ ព្រោះ ដីនេះជាដីរបស់ម្តាយខ្លួនៗនៅសល់តែដីបន្តិចបន្តួចប៉ុណ្ណោះ ហើយសព្វថ្ងៃខ្លួនអត់ទាន់មានដីសំរាប់ធ្វើផ្ទះស្នាក់ នៅៗឡើយ ។ ចំពោះ ទុយ សារ៉េត គាត់មានដីជាចំណែករបស់គាត់ត្រឹមត្រូវ ហើយបែរជាគាត់មកទាមទារ យកដីរបស់ម្តាយខ្លួនទៅវិញ ដូច្នេះខ្លួនមិនអាចប្រគល់ដីនេះឱ្យទៅគាត់បានឡើយ ។

សូមឯកឧត្តម មេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

យល់ឃើញថា : បណ្តឹងសាទុក្ខលេខៈ ៣៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០០ របស់អ្នកស្រី ទុយ សារ៉េត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា : ការអ្នកស្រីទុយ សារ៉េត លើកឡើងក្នុងសារណាការពាររបស់ខ្លួននោះគឺជាការភន្តច្រឡំ ពីព្រោះថា :

- អ្នកស្រី ណុប វិត និង ប្តីឈ្មោះ ឆាង សារឿន ជាប្តីប្រពន្ធនឹងគ្នា ពុំមានសាលក្រមណាសំរេចពីការលែងលះគ្នាទេ ។ ទោះបីអ្នកស្រី ណុប វិត បានចេញទៅរកស៊ីពីឆ្នាំ១៩៨៨រហូតដល់ឆ្នាំ១៩៩៧ក្តី ក៏អ្នកស្រីមានប្តីរស់នៅជាប់ជាប្រចាំលើដីទំនាស់ជាមួយកូនដែរ ។ ចំពោះការតាំងទីលំនៅលើដីទំនាស់របស់អ្នកស្រី ទុយ សារ៉េត ទោះបីជាមានការព្រមព្រៀងពីឈ្មោះ ឆាង សារឿន ក្តីក៏អ្នកស្រី ទុយ សារ៉េត ពុំអាចឡើងជាកម្មសិទ្ធិករលើដីទំនាស់នេះបានដែរ ព្រោះថា ទ្រព្យរួមសម្បាច់រវាងប្តី ប្រពន្ធណុប វិត និង ឆាង សារឿន បើយោងតាមមាត្រា ២០ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២។

យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខៈ ៨៣០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ទាំងគតិច្បាប់។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១ - ទទួលបណ្តឹងសាទុក្ខលេខៈ ៣៩ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ២០០០ របស់អ្នកស្រី ទុយ សារ៉េត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខៈ ៨៣០ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ទុយ សារ៉េត បានបង់ទុកនៅតុលាការកំពូល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល។

បង្គាប់ឱ្យអ្នកស្រី ទុយ សារ៉េត បង់ ពន្ធសមាមាត្រចំនួន មួយភាគរយនៃ តម្លៃដីទំនាស់ តាមការកំណត់របស់តុលាការថ្នាក់ក្រោម ។

៤ - សាលដីកានេះប្រកាសនាសវនាការជា សាធារណៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២.០០៤។